Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group

# របាយការណ៍ត្រីមាសទី២

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី២ឆ្នាំ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៦ ៩៧៦ ៤៩៥ | ៦ ៣៧០ ៨៥០ | ៤ ៩៩៩ ៣២៣ |
| បំណុលសរុប (លានរៀល) | ៥ ៧៧៤ ៧១៩ | ៥ ៣២០ ៦២៥ | ៤ ១៩១ ០០៦ |
| មូលធនសរុប (លានរៀល) | ១ ២០១ ៧៧៦ | ១ ០៥០ ២២៥ | ៨០៨ ៣១៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី២ឆ្នាំ២០២១** | **ត្រីមាសទី២ឆ្នាំ ២០២០** | **ត្រីមាសទី២ឆ្នាំ ២០១៩** |
| ចំណូលសរុប (លានរៀល) | ២១៤ ៩០៤ | ១៧០ ២០២ | ១៤២ ៦៩៤ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | (១៦ ២៤៩) | (១៧ ៤៧២) | ៣២ ១១៨ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ(លានរៀល) | (១២ ៨៩៨) | (១៤ ០១១) | ២៥ ៦៦២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | (១១ ៨៣៧) | (១៥ ២៨៥) | ២៩ ៤៥៧ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី២ឆ្នាំ២០២១** | **២០២០** | **២០១៩** |
| អនុបាតសាធនភាព (ភាគរយ) | ១៩,៦ | ១៧,៨ | ១៩,៤ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤៨១ | ៥០៧ | ៥១៨ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ២៣៥,០ | ១៣១,០ | ១១៣,៩ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ១,៤៩ | ១,៣១ | ០,៣០ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៦១,៧ | ៥៩,៩ | ៥៧,០ |
| | **ត្រីមាសទី២ឆ្នាំ២០២១** | **ត្រីមាសទី២ឆ្នាំ ២០២០** | **ត្រីមាសទី២ឆ្នាំ ២០១៩** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | (០,១៨) | (០,២៦) | ០,៦១ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | (១,០៧) | (១,៤៥) | ៣,៤៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ៨២ | ៧៥ | ១៥៤ |



[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# គ្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



លោក Pairote CHEUNKRUT
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

សេដ្ឋកិច្ចសកលលោកនៅចុងត្រីមាសទី២ បានឃើញថាមានការស្ទុះងើបឡើងវិញជាវិជ្ជមាននៅក្នុងទីផ្សារជាច្រើន ដោយសារលទ្ធផលនៃការចាក់វ៉ាក់សាំង និងវិធានការគ្រប់គ្រងការពារនៅក្នុងប្រទេសសេដ្ឋកិច្ចធំៗ ។ ម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា បានកំពុងស្ថិតនៅលើនិន្នាការរស់ឡើងវិញ តាមរយៈការបង្កបង្កើនផលទៅលើវិស័យ កសិកម្ម និងផលិតកម្មនាំចេញដ៏រឹងមាំ ទោះយ៉ាងណាក៏ដោយវិស័យទេសចរណ៍ និងវិស័យកាត់ដេរសម្លៀកបំពាក់ នៅតែងាយរងគ្រោះ។

សម្រាប់ត្រីមាសនេះ ធនាគារ ហត្ថា ម.ក បានធ្វើការយ៉ាងជិតស្និទ្ធជាមួយធនាគារ ក្រុងស្រី ដោយបានដាក់ចេញនូវវិធានការចាំបាច់មួយចំនួន នៅក្នុងកាលៈទេសៈនៃការកើនឡើងករណីឆ្លងជំងឺកូវីដ១៩ និងការបិទខ្ទប់រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលនៅអំឡុងខែមេសា និងឧសភា ដើម្បីធានាបាននូវស្ថានភាពសាច់ប្រាក់គ្រប់គ្រាន់ និងការត្រៀមខ្លួនសម្រាប់ពង្រីកផលប័ត្រនៅពេលស្ថានការណ៍ប្រសើរឡើងវិញ។ ធនាគារ ក្រុងស្រី បានបន្ថែមដើមទុនចំនួន ២៥ លានដុល្លារអាមេរិកទៀត ទៅឲ្យធនាគារ ហត្ថា ម.ក ដែលធ្វើឱ្យដើមទុនសរុបសព្វថ្ងៃមានចំនួន ១៤០ លានដុល្លារអាមេរិក។ នៅចុងត្រីមាសនេះ ផលប័ត្រឥណទាន គឺរក្សាបានចំនួន ១ ៤១៨ លានដុល្លារអាមេរិក សមតុល្យប្រាក់បញ្ញើសន្សំបានកើនឡើងដល់ ៨៧៥ លានដុល្លារអាមេរិក គឺកើនឡើង ៦,៦% បើធៀបនឹងត្រីមាសមុន ហើយឥណទានមិនដំណើរការ បានកើនឡើងដល់ ១,២១% ដែលរងផលប៉ះពាល់ពីការបិទខ្ទប់ រីឯអនុបាតគ្របខណ្ឌសន្ទនីយភាព LCR មានចំនួន ២៣៥% ខ្ពស់ជាងការកំណត់របស់និយ័តករត្រឹមតែ ១០០%។ បន្ទាប់ពីការបង្កើនដើមទុន អនុបាតសោធនភាពរបស់ធនាគារមានចំនួន ១៩,៦% ហេតុនេះ អារម្មណ៍អាជីវកម្មសម្រាប់នៅចុងត្រីមាសនេះ បានធ្វើឱ្យប្រសើរឡើងដោយសមហេតុផល ហើយយើងមានសង្ឃឹមថា សន្ទុះនឹងនៅតែបន្តទៅមុខដល់ត្រីមាសក្រោយៗទៀត។

ជាមួយនឹងការរីករាលដាលនៃជំងឺរាតត្បាតនេះ ធនាគារ ហត្ថា ម.ក បានផ្តល់ការគាំទ្រដល់អតិថិជនតាមរយៈ ការរៀបចំឥណទានសារឡើងវិញ ជូនដល់អតិថិជនជាង ៣៣ ០០០ នាក់ ស្មើនឹងចំនួនទឹកប្រាក់ប្រហែលជិត ៣២១ លានដុល្លារអាមេរិក។ ការប្រើប្រាស់ធនាគារចល័តរបស់យើង បានកើនឡើង ២៦% ស្មើនឹងចំនួនអ្នកប្រើប្រាស់៣០ ០០០ នាក់ ដែលផ្តល់នូវភាពងាយស្រួល និងសុវត្ថិភាពសម្រាប់អតិថិជនក្នុងការធ្វើប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗ ដោយរក្សាបាននូវគម្លាតសង្គម។ ធនាគារ ក៏បានដាក់ចេញនូវវិធានការបង្ការចាំបាច់ ដើម្បីធានា ថែរក្សា ការពារបុគ្គលិករបស់ខ្លួន ជាឧទាហរណ៍ដូចជា ឧបករណ៍តេស្តរហ័សសម្រាប់បុគ្គលិក ការធ្វើការងារពីផ្ទះ និងការបែងចែកកន្លែងធ្វើការ ក្នុងការកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ១៩។

នៅត្រីមាសបន្ទាប់ទៀត ធនាគារ ហត្ថា ម.ក មានគម្រោងចាប់ផ្តើមតំណាក់កាលទី ១ ចំពោះការសាងសង់ការិយាល័យកណ្តាលធនាគារពាណិជ្ជថ្មីរបស់ខ្លួន ដែលនឹងក្លាយជាទីតាំងដ៏សំខាន់របស់យើង ដើម្បីបម្រើអតិថិជនរបស់ធនាគារសម្រាប់រយៈពេលវែង។ សម្រាប់ការផ្ទុះឡើងនូវជំងឺកូវីដ១៩ ជាបន្តបន្ទាប់នេះ ខ្ញុំសូមជូនពរដល់អ្នករាល់គ្នាឲ្យមានសុវត្ថិភាព និងរឹងមាំក្នុងការទប់ទល់ជាមួយនឹងស្ថានការណ៍នេះ ហើយធនាគារ ហត្ថា ម.ក នឹងនៅតែបន្តគាំទ្រដល់អតិថិជនរបស់ខ្លួនជាមួយនឹងស្ថានភាពបែបនេះដែរ។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២១

ហត្ថលេខា និង ត្រា

លោក Dan HARSONO

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្ដីថ្លែងរបស់ប្រធានអគ្គនាយក

នៅក្នុងត្រីមាសទី២នៃឆ្នាំ២០២១នេះ គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់គ្នារបស់ធនាគារ ហត្ថា ម.ក បានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ជាមួយនឹងការលះបង់ខ្ពស់ក្នុងការអនុវត្តការងារទៅតាមផែនការយុទ្ធសាស្ត្រ ដែលបានកំណត់ បើទោះបីជាមានការរាំងស្ទះ ឬគំរាមកំហែងខ្លាំងពីជំងឺកូវីដ១៩ ដោយបានរាតត្បាតនៅក្នុងសហគមន៍ ក៏ដោយ។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ធនាគារ ហត្ថា ម.ក បានទទួលលទ្ធផលល្អប្រសើរដូចខាងក្រោម៖

-សមតុល្យប្រាក់កម្ចីលើសផែនការ ៨,២៨%
-ប្រាក់បញ្ញើសន្សំលើសផែនការ ១៧,១៣%
-ឥណទានមិនដំណើរការគឺ ១,២១%ល្អប្រសើរជាងផែនការចំនួន ០,៥៥%

ពេលវេលាចេះតែទៅមុខមិនរង់ចាំយើងទេ ដូច្នេះយើងក៏មិនអាចរង់ចាំរហូតដល់ជំងឺកូវីដ១៩រលត់បាត់ទៅវិញ ទើបយើងចាប់ផ្តើមធ្វើសកម្មភាពទេ ហេតុដូច្នេះហើយបានជា គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់បាននឹងកំពុងបន្តខិតខំប្រឹងប្រែងបំពេញការងារ ទៅតាមតួនាទីរៀងៗខ្លួន ដើម្បីសម្រេចឲ្យបានតាមគោលដៅ និងតាមផែនការយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់ធនាគារ ហត្ថា ម.ក។ លើសពីនេះទៅទៀត ធនាគារ ហត្ថា ម.ក បានកំពុងដំឡើងជំនាន់ប្រព័ន្ធធនាគារស្នូលថ្មី សម្រាប់បំពេញតម្រូវការអតិថិជន ដែលបានដាក់ឲ្យដំណើរការកាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០២១ ដោយជោគជ័យ។

ការរីករាតត្បាតនៃជំងឺកូវីដ១៩ ហាក់បីដូចជាមិនទាន់បានធូរស្រាលនៅឡើយទេ អ្នកឆ្លង និងអ្នកស្លាប់ដោយសារជំងឺកូវីដ១៩នេះ មានការកើនឡើងជារៀងរាល់ថ្ងៃ ដូចនេះ សូមអំពាវនាវឲ្យបុគ្គលិកគ្រប់ជាន់ថ្នាក់ បន្តអនុវត្តវិធានការការពាររបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាឲ្យបានជានិច្ច បើទោះបីជាបានចាក់វ៉ាក់សាំងរួចហើយក៏ដោយ ត្រូវចេះ **ស្រលាញ់គ្រួសារ ស្រលាញ់ខ្លួន ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន ពាក់ពាការពារ**។

ជាចុងក្រោយ ខ្ញុំសូមជូនពរដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ឲ្យមានសុខភាពល្អ សំណាងល្អ រកទទួលទានមានបាន និងសុខដុមរមនានៅក្នុងគ្រួសារជៀសផុតពីជំងឺកូវីដ១៩។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២១
ហត្ថលេខា

លោកឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក

# មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ i
ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ ii
សមាសភាពក្រុមប្រឹក្សាភិបាល ........ iii
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ........ iv
សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ........ v
ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........ ១
ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ........ ១
ខ- លក្ខណៈនៃធុរកិច្ច ........ ១
គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........ ២
ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣
ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ........ ៣
ខ- រចនាសម្ព័ន្ធចំណូល ........ ៤
ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ ៥
ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ ៦
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ ៦
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ ៦
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ ៦
ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ ៦
ង- ផលប៉ះពាល់នៃអតិផរណា ........ ៧
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ........ ៧

## ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារ ហត្ថា ម.ក |
| ឈ្មោះជាអក្សរឡាតាំង | Hattha Bank Plc. |
| កូដស្តង់ដារ | KH20000718B4 |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hatthabank.com |
| អ៊ីម៉ែល | info@hatthabank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៩៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ-៥៦ ចេញដោយ: ធនាគារជាតិនៃកម្ពុជាកាលបរិច្ឆេទ: ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងធនាគារ ហត្ថា ម.ក ដោយ | លោកឧកញ៉ា ហួត អៀងតុង |

### ខ- លក្ខណ:នៃធុរកិច្ច

ធនាគារ ហត្ថា ម.ក គឺជាធនាគារមួយក្នុងចំណោមធនាគារឈានមុខផ្សេងទៀតនៅកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០។ ជាមួយបទពិសោធន៍ក្នុងការបម្រើសេវាហិរញ្ញវត្ថុទៅកាន់ប្រជាជនកម្ពុជាអស់រយៈពេលជិត ៣០ឆ្នាំ ក្រោយការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ខ្លួន ធនាគារ ហត្ថា ម.ក បានកែលម្អ និងដាក់ឱ្យប្រើប្រាស់បន្ថែមនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផ្សេងទៀតក្នុងនោះមានដូចជា៖ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័ត (Hattha Mobile) ដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ឆ្លងធនាគារ សេវាឥណទានវិបារូបន៍ សេវាបញ្ញើសន្សំ (គណនីចរន្ត គណនីHYSA Flexi និង HYSA Corporate) និងការត្រៀមខ្លួនក្នុងការផ្តល់ជូនសេវាធនាគារថ្មីៗផ្សេងទៀត បន្ថែមលើសេវាដែលមានស្រាប់ដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាបើកប្រាក់បៀវត្ស សេវាទូទាត់វហ័ស សេវាប្រមូលសាច់ប្រាក់ និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ។

គិតត្រឹម ខែ មិថុនា ឆ្នាំ ២០២១ សមតុល្យប្រាក់បញ្ញើសន្សំ របស់ ធនាគារ ហត្ថា ម.ក មានចំនួនជាង ៨៧៥ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនប្រាក់បញ្ញើសន្សំ ២៧៨ ៧០២ នាក់ និងផលប័ត្រឥណទានសរុបមាន

ចំនួនប្រមាណ ១ ៤១៨ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៩០ ១១៧ នាក់ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំង នៅទូទាំងប្រទេស។

ធនាគារ ហត្ថា ម.ក គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ ក្រុងស្រី។ ធនាគារ ក្រុងស្រី (ធនាគារ អាយុធ្យា ម.ក និងក្រុមហ៊ុនជាបុត្រសម្ព័ន្ធ) គឺជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅក្នុងព្រះរាជាណាចក្រថៃ ដោយយោងលើទំហំទ្រព្យសកម្ម ផលប័ត្រឥណទាន និងប្រាក់បញ្ញើសន្សំ និងជាធនាគារមួយក្នុងចំណោមធនាគារ D-SIBs ចំនួនប្រាំ ដែលបានធ្វើប្រតិបត្តិការអាជីវកម្មជូនអតិថិជនរបស់ខ្លួនអស់រយៈពេល ៧៦ ឆ្នាំ មកហើយនៅក្នុងព្រះរាជាណាចក្រថៃ។ ធនាគារ ក្រុងស្រី គឺជាសមាជិកយុទ្ធសាស្ត្ររបស់សម្ព័ន្ធហិរញ្ញវត្ថុ MUFG ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបង្អស់នៅជប៉ុន ក៏ដូចជាសម្ព័ន្ធហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំៗផ្សេងទៀតនៅលើពិភពលោក។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

ជំងឺកូវីដ-១៩ គឺជាវិបត្តិសកលលោកមួយដែលជាបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់យើងទាំងអស់គ្នានាមួយរយៈកាលចុងក្រោយនេះ។ ទោះយ៉ាងនេះក្តី ធនាគារ ហត្ថា ម.ក នៅតែរក្សាប្រតិបត្តិការរឹងមាំរបស់ខ្លួនដោយមានការជឿទុកចិត្តពីសំណាក់អតិថិជន សាធារណជន និងអ្នកពាក់ព័ន្ធទាំងអស់។ ស្របតាមគោលដៅអាជីវកម្មរយៈពេលវែងរបស់ខ្លួននៅត្រីមាសទី ២ ឆ្នាំ ២០២១ ធនាគារ ហត្ថា ម.ក បានអនុវត្ត និងសម្រេចបាននូវសកម្មភាពការងារសំខាន់ៗជាច្រើនដើម្បីគាំទ្រដល់ភាពរីកចម្រើននៃប្រតិបត្តិការរបស់ខ្លួន រួមមាន៖ ការចាប់ផ្តើមបុកគ្រឹះសាងសង់អគារការិយាល័យកណ្តាលថ្មីដែលមានទំហំសំណង់ប្រមាណជាង ៤០ ០០០ ម៉ែត្រក្រឡា តាមបណ្តោយផ្លូវសម្តេចតេជោហ៊ុនសែន ឬផ្លូវ៦០ម៉ែត្រ។ អគារការិយាល័យកណ្តាលថ្មីដ៏ធំស្កឹមស្កៃនេះ បានរៀបចំពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ដោយមានការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់របស់ ធនាគារ ហត្ថា ម.ក និងក្រុមហ៊ុនស៊ីអឹមអ៊ីឌី ខនស្រ្តាក់សិន ម.ក ដែលជាក្រុមហ៊ុនទទួលខុសត្រូវក្នុងការសាងសង់។

ទោះបីជាស្ថិតនៅក្នុងពេលវេលាដ៏សែនលំបាកនៃការរីករាលដាលជំងឺកូវីដ១៩ ក៏ធនាគារ ហត្ថា ម.ក ទទួលបានជោគជ័យធំៗបន្ថែមទៀតនោះគឺ ការទទួលបាននូវទំនុកចិត្តខ្ពស់ពីភាគទុនិកជាមួយការចាក់បញ្ចូលនូវដើមទុនចុះបញ្ជីបន្ថែមរហូតដល់ ២៥ លានដុល្លារអាមេរិក និងទទួលបានចំណាត់ថ្នាក់ BBB+/Stable រយៈពេល 0៤ឆ្នាំជាប់ៗគ្នា (ដែលការវាយតម្លៃតែលើធនាគារ ហត្ថា ម.ក ទទួលបានចំណាត់ថ្នាក់ A-) ពី TRIS Rating ដែលជាស្ថាប័នអន្តរជាតិមកពីប្រទេសថៃ។

ជាធនាគារដែលមានការទទួលខុសត្រូវខ្ពស់ចំពោះសង្គមជាតិដែលខ្លួនកំពុងរស់នៅ ធនាគារ ហត្ថា ម.ក តែងតែចូលរួមចំណែកក្នុងសកម្មភាពសង្គមជាច្រើនក្នុងន័យរួមគ្នាកសាងអនាគតដ៏ប្រសើរ ដែលជាលទ្ធផល ធនាគារ ហត្ថា ម.ក បានបរិច្ចាគគ្រែពេទ្យចំនួន ១០ ជូនដល់មន្ទីរពេទ្យបង្អែកឧដុង្គ។ ការចូលរួមបរិច្ចាគនេះផងដែរ គឺធ្វើឡើងក្នុងគោលបំណងឱ្យប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាំងមូលទទួលបានសេវាថែទាំសុខភាព និងការថែទាំជំងឺពេញលេញប្រកបដោយផាសុកភាពបំផុត ជាពិសេសស្របពេលដែលមន្ទីរពេទ្យកំពុងតែត្រូវការគ្រែជាចាំបាច់សម្រាប់ត្រៀមថែទាំអ្នកជំងឺក្នុងអំឡុងពេលដែលជំងឺកូវីដ១៩ កំពុងតែរីករាលដាលយ៉ាងខ្លាំងក្នុងប្រទេសកម្ពុជាយើងផងដែរ។

លើសពីនេះទៅទៀត ធនាគារ ហត្ថា ម.ក ក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ជំហានបន្ទាប់របស់ខ្លួនដើម្បីផ្តល់ជូនអតិថិជននូវបទពិសោធន៍កាន់តែប្រសើរ តាមរយៈការសិក្សាអំពីការធ្វើឱ្យប្រសើរឡើងនូវសេវាធនាគារចល័តរបស់ខ្លួន (UX / UI) និងសិក្សាលើការបង្កើតការស្នើសុំលេខគណនីពិសេសសម្រាប់អតិថិជន ក៏ដូចជាសេវាហិរញ្ញវត្ថុជាច្រើនទៀតដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការជំរុញបន្ថែមដល់ភាពរីកចម្រើនរបស់ពួកគាត់ឱ្យកាន់តែឆាប់រហ័សផងដែរ។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៨៥ ០៩៤ | ១៩០ ១១៧ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ៣០៩ ៦៧៦ | ១ ៤១៨ ០៨៦ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៧៩ ៤៦៨ | ២៧៨ ៧០២ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៧៤៧ ៣៤៨ | ៨៧៥ ៣៩៩ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៧៥ ២៥៣ | ៥៩ ១៦៨ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៣៨ ៤០៨ | ២៩ ៧៥៧ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ៣០៥ ៦០០ | ១២៣ ៣៥៦ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ៤ ០៦៦ ៨៣៣ | ៤ ៧២៨ ០២៨ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៥៧ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ៨៩៣ | ៥ ៤៧៥ |

ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ ២០២១ | | ត្រីមាសទី២ ឆ្នាំ២០២០ | | ត្រីមាសទី២ ឆ្នាំ ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ២១០ ៣០៨ | ៩៧,៩ | ១៦៧ ០៤៣ | ៩៨,១ | ១៣៨ ០៦៣ | ៩៦,៨ |
| ២ | ចំណូលផ្សេងៗ | ៤ ៥៩៦ | ២,១ | ៣ ១៥៩ | ១,៩ | ៤ ៦៣១ | ៣,២ |
| ចំណូលសរុប | | ២១៤ ៩០៤ | | ១៧០ ២០២ | | ១៤២ ៦៩៤ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០២១ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២១។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ធនាគារ ហត្ថា ម.ក ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗ ដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ធនាគារ ហត្ថា ម.ក តែប៉ុណ្ណោះ ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**ការវិភាគចំណូល**

ធនាគារ ហត្ថា ម.ក មានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ធនាគារ ហត្ថា ម.ក ដែលមានរហូតដល់ ៩៧,៩% នៃចំណូលសរុប។

### ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាមានផលប៉ះពាល់ជាអវិជ្ជមាននៃការបិទខ្ទប់ «ព្រឹត្តិការណ៍ ២០ កុម្ភៈ» មកលើអាជីវកម្មរបស់ធនាគារនៅក្នុងត្រីមាសនេះ ជាលទ្ធផលធ្វើឱ្យធនាគារខាតនៅក្នុងត្រីមាសនេះផងដែរ ។លទ្ធផលនេះ មកពីការកើនឡើងយ៉ាងខ្លាំងនៃការចំណាយលើឱនភាពតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ។

### គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាការលក់ និងចំណូលមានការកើនឡើងនៅក្នុងដំណាក់កាលកូវីដ១៩នេះ។

### ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារ ហត្ថា ម.ក បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

## ង- ផលប៉ះពាល់នៃអតិផរណា

ធនាគារ ហត្ថា ម.ក មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការដែលមានស្រាប់សំខាន់ៗជាច្រើនដើម្បីធានាឱ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ចជាតិ ដូចជាការបន្តផ្តល់ហិរញ្ញប្បទាន គាំទ្រនិយោជិតដែលត្រូវបានព្យួរការងារ (ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ស្បែកជើង និងទេសចរណ៍) និងគ្រួសារដែលមានប័ណ្ណក្រីក្រ ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ១៩។
គោលនយោបាយពាក់ព័ន្ធទាំងនេះរួមមាន៖

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានចេញវិធានការអនុគ្រោះដំណាក់កាលទី៣របស់ខ្លួនដើម្បីចូលរួមគាំទ្រគោលនយោបាយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈម និងសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩។ វិធានការអនុគ្រោះទាំងនោះរួមមាន (១) រក្សាការអនុវត្តប្រាក់បម្រុងកាតព្វកិច្ចតាមអត្រា ៧% ដដែលរហូតដល់មានការជូនដំណឹងជាថ្មីពីធនាគារជាតិនៃកម្ពុជា (២) អនុញ្ញាតិឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបន្តឥណទានរៀបចំឡើងវិញរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ចំពោះអតិថិជនដែលរស់នៅទីតាំងតំបន់បិទខ្ទប់តាមការកំណត់របស់រាជរដ្ឋាបាល ឬអាជ្ញាធរពាក់ព័ន្ធ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចធ្វើឥណទានរៀបចំឡើងវិញលើសពី៣ដង ក្នុងអំឡុងពេលអនុគ្រោះនេះ និង (៣) បន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពិនិត្យលទ្ធភាពអនុគ្រោះបន្ធូរបន្ថយឬលើកលែងការយកសោហ៊ុយឬការពិន័យផ្សេងៗតាមស្ថានភាពជាក់ស្តែងរបស់អតិថិជន។
ជាបន្តមកទៀត នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានសម្រេចចិត្ត នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ក្នុងគោលដៅដើម្បី (១) បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ (២) បន្តផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការ LPCO ដើម្បីឆ្លើយតបនឹងតម្រូវការសន្ទនីយភាពជាប្រាក់រៀលរយៈពេលខ្លីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និង (៣) បន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ច ក្នុងអត្រា ៧% ទាំងប្រាក់រៀល និងដុល្លារអាមេរិក។

បន្ថែមជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជា សម្រេចចិត្តបន្តសុពលភាពនៃវិធានការដែលបានដាក់ចេញនាពេលកន្លងមក ដើម្បីបន្តគាំទ្រដល់ប្រជាពលរដ្ឋ និងអាជីវកម្ម ដែលបាននឹងកំពុងរងផលប៉ះពាល់ពីជំងឺកូវីដ១៩។ គោលបំណងនៃការបន្តនេះ គឺការជួយគាំទ្រសង្គម/សេដ្ឋកិច្ច និងការការពារពីការរីករាលដាលជំងឺកូវីដ១៩ក្នុងសហគមន៍កម្រិតធំ ការបន្តរាល់កម្មវិធីទំនុកបម្រុងដែលមានស្រាប់ ការជួយគាំពារឱ្យអាជីវកម្មទាំងឡាយអាចសម្របខ្លួនទៅតាមស្ថានភាព “ធម្មតាថ្មី” និងការបន្តរាល់កម្មវិធីជួយទំនុកបម្រុងផ្នែកហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ និងប្រជាជនដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩។

## ហត្ថលេខារបស់អភិបាល ធនាគារ ហត្ថា ម.ក

កាលបរិច្ឆេទ៖ ១៣ ខែ សីហា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ១៣ ខែ សីហា ឆ្នាំ២០២១
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

ហត្ថា
Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group